# ហេតុអ្វីត្រូវការសង្គ្រោះប្រោសសត្វលោក

ម្ចាស់បង្កើតលោកហេតុអ្វីត្រូវការសង្គ្រោះប្រោសសត្វលោក! ដោយសារគាត់ស្រឡាញ់សត្វលោក! ដោយសារជីវិតរបស់សត្វលោកសុទ្ធតែជាគាត់ប្រទានឲ្យ។

ពេលរាងកាយលោកធាតុនៅបង្គ, នឹងថេរ, អន្តរាយ, ពន្លត់បានដល់ចុងក្រោយរួចហើយ, ម្ចាស់បង្កើតលោកប្រើពេលវេលា២០០លានឆ្នាំបង្កជាត្រៃភព, រៀបចំឲ្យសត្វលោកទម្រង់គ្រប់ប្រភេទនិងវាសនាដើម្បីបានសង្គ្រោះ, ក្នុងពេលដំណាលគ្នាដាក់កំណត់វប្បធម៌និងមនោគតិចរិយារបស់មនុស្ស។ គាត់ថែមទាំងប្រើកាយអាទិទេពរបស់ខ្លួនឯងដើម្បីរំលាយដោះទោសកម្មឲ្យសត្វលោក! ដើម្បីសង្គ្រោះសត្វលោកទ្រង់បានបង់ចំណាយទាំងអស់របស់ខ្លួនឯង។

ព្រោះដើម្បីនៅវេលាចុងក្រោយចាប់ផ្ដើមសង្គ្រោះប្រោសមនុស្សអាចសម្រេចបានដល់តម្រូវរបស់អាទិទេព, ក្នុង២០០លានឆ្នាំ{គឺ}អនែកបំបែកកាយនៃម្ចាស់បង្កើតលោកចាប់កំណើតឡើងវិញនៅលើលោកីយ៍ដើម្បីត្រួសត្រាយទ្រាប់វប្បធម៌មនុស្សជាតិ, មើល{ថែ}រក្សាសីលធម៌របស់មនុស្ស។ នៅក្នុងឆ្នាំខែយឺតនិងយូរនៃប្រវត្តិសាស្ត្រ, ជីវិតវិលកើតវិលស្លាប់បង្វិលរាប់ពាន់ម៉ឺនឆ្នាំធ្វើដំណើរជុំដើម្បីរង់ចាំ, បន្តិចម្ដងរាងកាយពិតរបស់ជីវិតមនុស្សលោកីយ៍(រួមបញ្ចូលបណ្ដាជាតិសាសន៍)ភាគច្រើនមានទំនាក់ទំនងសាច់ញាតិគ្រប់ប្រភេទជាមួយនឹងម្ចាស់បង្កើតលោក, នេះធ្វើឲ្យម្ចាស់បង្កើតលោកកាន់តែ

ស្រឡាញ់មនុស្សលោកីយ៍របស់ទ្រង់។ ពេលដល់ចុងក្រោយរួចហើយ, ដើម្បីបង្ហើយល្អជាងរឿងសង្គ្រោះប្រោស, ជីវិតគ្មានប្រភេទទំនាក់ទំនងនេះជាមួយនឹងម្ចាស់បង្កើតលោកគឺមិនអាចធ្វើមនុស្សក្នុងពេលនេះ, ដល់ពេលនេះសច្ចៈកាយរបស់មនុស្សលោកីយ៍បានសុទ្ធតែជាមនុស្សរបស់ទ្រង់, គឺសូម្បីតែអាទិទេពទាំងនោះដែលមនុស្សលើលោកីយ៍ជំនឿ, មនុស្សដែលកេងប្រវ័ញ្ចចាប់កំណើតកើតជាមនុស្សមកសម្តែងធម៌, សម្តែងតារ, ក៏សុទ្ធតែជាមនុស្សរបស់ម្ចាស់បង្កើតលោក។ គោលបំណងអាទិទេពប្រើរាងកាយមនុស្សព្រោះដើម្បីម្ចាស់បង្កើតលោកសង្គ្រោះប្រោសមនុស្សលោកីយ៍ចុងក្រោយដើម្បីត្រួសត្រាយទ្រាប់វប្បធម៌របស់អាទិទេព, បន្សល់ទុកសាសនាសុចរិតគ្រប់ប្រភេទក៏ជាដើម្បីរក្សាសីលធម៌មនុស្សជាតិហើយស្ថិតនៅ, រង់ចាំសង្គ្រោះប្រោសចុងក្រោយរបស់ម្ចាស់បង្កើតលោក។ ចំពោះម្ចាស់បង្កើតលោកដើម្បីនិយាយ, ទ្រង់មានសិទ្ធិស្រឡាញ់មនុស្សរបស់ទ្រង់, ទ្រង់ក៏នឹងកាន់តែស្រឡាញ់មនុស្សដែលទ្រង់សន្មតថាគួរតែស្រឡាញ់។ នោះគឺសិទ្ធិប្រយោជន៍របស់ទ្រង់, នរណាក៏គ្មានសិទ្ធិជ្រៀតជ្រែក! នោះជាព្រះគុណដ៏ខ្ពង់ខ្ពស់បំផុតនៃទ្រង់ចំពោះជីវិត។

ម្ចាស់បង្កើតលោកគឺជាម្ចាស់នៃអាទិទេពទាំងអស់ក្នុងរាងកាយលោកធាតុ, ទ្រង់ជាអង្គបង្កចេញម្ចាស់នៃម៉ឺនម្ចាស់, ស្តេចនៃម៉ឺនស្តេច, មេត្រួតត្រាទាំងអស់របស់សត្វលោក, រួមបញ្ចូលទាំងមនុស្ស, អាទិទេព, វត្ថុទាំងអស់ក្នុងត្រៃភពដែលទ្រង់បង្ក។ ស្នេហារបស់ទ្រង់គឺជាព្រះ

គុណដ៏វិសុទ្ធខ្ពស់បំផុតចំពោះសត្វលោក! មនុស្សលោកីយ៍បានទ្រង់ស្រឡាញ់គឺជាកិត្តិយសធំបំផុតរបស់មនុស្ស។

*គ្រូ៖ លីហុងជឺ*

*ថ្ងៃ១៧ខែមេសាឆ្នាំ២០២៣*

**ចំណាំ៖** (*ចំណាំគឺជារបស់អ្នកបកប្រែចិន-ខ្មែរ, គ្រាន់តែទុកជាឯកសារយោង*)

បកប្រែពីភាសាចិនដើម៖

https://www.minghui.org/mh/articles/2023/4/17/458929.

ពិគ្រោះការបកប្រែជាភាសាអង់គ្លេស៖

https://en.minghui.org/html/articles/2023/4/18/208128.

បកប្រែថ្ងៃ៖ ២៤-១០-២០២៣, កែសម្រួលថ្ងៃ២៦-១០-២០២៣, អត្ថបទបកប្រែអាចបានកែសម្រួលក្នុងពេលអនាគតដើម្បីកៀកន័យជាងនឹងអត្ថបទដើម។

**សច្ចៈកាយ៖** ផ្នែករាងកាយពិត។ ផ្នែករាងកាយសាច់របស់មនុស្សដែលភ្នែកសាច់មើលឃើញគ្រាន់តែជាផ្នែកខាងក្រៅ, ហើយមិនមែនជាទាំងអស់រាងកាយទាំងមូល។